**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៧...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការទទួលស្គាល់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**



www.pheakdeylaw.com

**មាត្រា ១.-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា" ឈ្មោះជាភាសាអង់គ្លេស "ACLEDA Institute of Business" សរសេរកាត់ជាភាសាខ្មែរ "វពអ" និងសរសេរកាត់ជាភាសាអង់គ្លេស "AIB" ។

**មាត្រា ២.-**

វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា មានទីតាំងស្ថិតនៅអគារលេខ៥០ ផ្លូវលេខ៥១៦ កែងនឹងផ្លូវលេខ៣៣៥ ភូមិ៦ សង្កាត់បឹងកក់មួយ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម មុខជំនាញហិរញ្ញវត្ថុ និងធនាគារ ។

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី កម្រិត ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី សុំប្តូរឈ្មោះថ្មី ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

នាយកវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា មានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវ ចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីការងារបណ្តុះបណ្តាល រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា ក្រោយជំណាច់ឆមាសទី២ ។

www.pheakdeylaw.com

**មាត្រា ៦._**

និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលសញ្ញាបត្រតាមកម្រិត ដែលបានសិក្សា ។ សញ្ញាបត្រនេះ ត្រូវផ្ដល់ដោយវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦*

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com